# តើពួកគេជាអ្នកណា?



ពួកគេ យកចិត្តទុកដាក់នឹងអ្នក



**ស្មរបន្ទាល់**ព្រះយេហូវ៉ាប្រាថ្នាចង់ឱ្យលោកអ្នកស្គាល់គេឱ្យបានច្បាស់ ។
លោកអ្នកប្រហែលជាបានជួបពួកគេ ដែលជាអ្នកជិតខាង ជានយោជិតជាមួយគ្នា
ឬក៏កាលដែលអ្នកកំពុងប្រព្រឹត្តសកម្មភាពណាមួយក្នុងជីវិតរៀងរាល់ថ្ងៃ ។
លោកអ្នកប្រហែលជាបានជួបប្រទះពួកគេតាមផ្លូវកាលដែលគេកំពុងតែប្រគល់ទស្សនាវដ្ដីដល់អ្នកដើរតាមផ្លូវនោះ ។
ឬក៏លោកអ្នកប្រហែលជាបាននិយាយដោយសង្ខេបជាមួយនឹងពួកគេនៅទ្វារផ្ទះរបស់លោកអ្នកដែរ ។

តាមការពិតទៅ
ស្មរបន្ទាល់ព្រះយេហូវ៉ាយកចិត្តទុកដាក់នឹងផលប្រយោជន៏របស់លោកអ្នកណាស់ ។
ពួកគេចង់ធ្វើជាមិត្តសំឡាញ់របស់លោកអ្នក
ហើយចង់ថ្លែងប្រាប់រឿងថែមទៀតអំពីខ្លួនគេ ជំនឿរបស់គេ អង្គការរបស់គេ
ហើយអំពីមនោសញ្ចេតនារបស់គេចំពោះមនុស្សនិងចំពោះពិភពលោក
ដែលយើងទាំងអស់គ្នាកំពុងរស់នៅក្នុងនោះ ។
ដើម្បីឱ្យជួយសម្រេចនូវគោលបំណងនេះ ពួកគេបានរៀបចំបោះពុម្ពសៀវភៅស្ដើងនេះសម្រាប់លោកអ្នក ។

តាមរបៀបភាគច្រើននោះ ស្មរបន្ទាល់ព្រះយេហូវ៉ាគឺដូចគ្នានឹងមនុស្សទាំងអស់ទៀតដែរ ។ ពួកគេមានបញ្ហាខាងសេដ្ឋកិច ខាងសាច់ឈាម ហើយខាងមនោសញ្ចេតនាជាដើម ។ ជួនកាលពួកគេធ្វើខុស ពីព្រោះគេមិនមែនជាមនុស្សល្អឥតខ្ចោះ
ឬមិនមែនជាមនុស្សមិនដែលភ្លាត់ធ្វើខុស
ហើយក៏មិនមែនជាមនុស្សដែលគ្រប់សកម្មភាពទាំងអស់សុទ្ធតែមកពីព្រះនោះឡើយ ។
ប៉ុន្តែពួកគេខំព្យាយាមរៀនពីពិសោធន៏របស់គេ ហើយគេយកចិត្តទុកដាក់នឹងសិក្សាព្រះគម្ពីរដើម្បីធ្វើការកែប្រែទាំងអស ដែលត្រូវការជាចាំបាច់ ។ គេបានឧទ្ទិសថ្វាយខ្លួនដល់ព្រះ ដើម្បីបំពេញតាមការឧទ្ទិសថ្វាយខ្លួនរបស់គេ ។
ពួកគេស្វែងរកការដឹកនាំពីបន្ទូលរបស់ព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ចំពោះកិច្ចការទាំងអស់របស់គេ ។

## ពួកគេបានថ្វាយខ្លួនដើម្បីប្រព្រឹត្តតាមបំណងព្រះហឫទ័យព្រះ

មានសារៈសំខាន់ណាស់ចំពោះស្មរបន្ទាល់ព្រះយេហូវ៉ា
ដែលជំនឿរបស់គេមានមូលដ្ឋានក្នុងព្រះគម្ពីរ
មិនស្រេចទៅលើការស្មានរបស់មនុស្ស
ឬក៏គោលជំនឿសាសនាប៉ុណ្ណោះឡើយ ។
ពួកគេមានគំនិតដូចជាសាវ័កប៉ុលកាលដែលលោកបានបញ្ចេញយោបល់ក្រោមអានុភាពនៃវិញ្ញាណបរិសុទ្ធរបស់ព្រះថាៈ

«សូមឱ្យព្រះបានរាប់ជាពិត ហើយគ្រប់ទាំងមនុស្សជាភូតភរវិញចុះ» ។ (រ៉ូម ៣:៤ *សមាគមខ្មែរនៃព្រះគម្ពីរបរិសុទ្ធ* *) ចំពោះការបង្រៀនដែលផ្សាយចេញជាសេចក្ដីពិតពីព្រះគម្ពីរ ពួកស្មរបន្ទាល់យល់ព្រមទាំងស្រុងនឹងការប្រព្រឹត្តរបស់ពួកបេរា កាលពួកគេបានឮសាវ័កប៉ុលធ្វើការផ្សាយនោះ «គេប្រុងប្រៀបសព្វគ្រប់នឹងទទួលព្រះបន្ទូល ក៏ពិចារណាមើលគម្ពីររាល់តែថ្ងៃ ឱ្យបានដឹងជាសេចក្ដីទាំងនោះត្រូវឬមិនត្រូវ» ។ (កិច្ចការ ១៧:១១) ស្មរបន្ទាល់ព្រះយេហូវ៉ាជឿថា ការបង្រៀនខាងសាសនាទាំងអស់ ទោះជាការបង្រៀនរបស់ពួកគេ ឬក៏របស់អ្នកដទៃក៏ដោយ នោះត្រូវតែយកមកពិចារណាដោយប្រើសេចក្ដីសាកល្បងនេះ ក្នុងកាលដែលលោកអ្នកមានការពិគ្រោះជាមួយនឹងពួកគេ ។

### ពួកគេជឿថាព្រះគម្ពីរគឺជាបន្ទូលរបស់ព្រះ

ដោយយល់នូវរឿងទាំងអស់នេះ ជាការជាក់ស្ដែងណាស់ដែលស្មរបន្ទាល់ព្រះយេហូវ៉ាជឿថា ព្រះគម្ពីរជាបន្ទូលរបស់ព្រះ ។ គេចាត់ទុកសៀវភៅទាំង៦៦ក្បាលជាបទគម្ពីរដែលត្រូវបានបណ្ដាលមកពីវិញ្ញាណបរិសុទ្ធរបស់ព្រះ ហើយថាជាការដ៏ត្រឹមត្រូវខាងប្រវត្តិសាស្ត្រផង ។ ផ្នែកដែលបានត្រូវហៅជាទូទៅថាសញ្ញាថ្មីនោះ ពួកគេហៅថាបទគម្ពីរគ្រីស្ទានភាសាក្រិកហើយគេហៅសញ្ញាចាស់ថាបទគម្ពីរភាសាហេព្រើរ ។ ពួកគេពឹងផ្អែកទៅលើបទគម្ពីរក្រិកនិងបទគម្ពីរហេព្រើរទាំងពីរ ហើយគេចាត់ទុកថាជារឿងអត្ថានុរូបទាំងអស់ លើកលែងតែកាលណាពាក្យសំដីឬក៏ហេតុការណ៍ដែលមានជុំវិញរឿងនោះ បង្ហាញយ៉ាងជាក់ស្ដែងថាជារឿងអត្ថបដិរូបឬជានិមិត្តរូបទៅវិញ ។ ពួកគេយល់ថាទំនាយជាច្រើនក្នុងព្រះគម្ពីរបានសម្រេចហើយ ។ ចំណែកទំនាយឯទៀតកំពុងតែសម្រេចឥឡូវ ហើយទំនាយផ្សេងៗទៀតនឹងត្រូវសម្រេចនៅអនាគតកាលដែរ ។

## ឈ្មោះរបស់ពួកគេ

តើជាស្មរបន្ទាល់ព្រះយេហូវ៉ាមែនឬ? មែនហើយ ពួកគេសំដៅចំពោះខ្លួនគេតាមឈ្មោះនេះ ។ ឈ្មោះនេះពណ៌នាអំពីគេ ដោយសម្ដែងថាគេធ្វើបន្ទាល់អំពីព្រះយេហូវ៉ា អំពីឋានៈរបស់ទ្រង់ ជាព្រះហើយអំពីគោលបំណងរបស់ទ្រង់ដែរ ។ «ព្រះ» «ព្រះយេហូវ៉ា» ហើយ «អ្នកបង្កើត» ដូចជា «ប្រធានាធិបតី» «ស្ដេច» ហើយ «ឧត្តមសេនីយ» គឺគ្រាន់តែជាឋានន្តរទេ ហើយអាចប្រើបានចំពោះបុគ្គលផ្សេងៗជាច្រើន ។ ក៏ប៉ុន្តែ «យេហូវ៉ា» ជាព្រះនាមផ្ទាល់របស់ទ្រង់ ហើយសំដៅចំពោះព្រះដ៏មានព្រះចេស្ដាបំផុត គឺជាអ្នកដែលបង្កើតសកលលោកទាំងមូល ។ រឿងនេះបានបង្ហាញឱ្យឃើញក្នុងទំនុកដំកើង ៨៣:១៨ ដែលចែងថា: «ដើម្បីឱ្យគេបានដឹងថាគឺទ្រង់តែ១អង្គព្រះនាមជាយេហូវ៉ា ដែលជាព្រះដ៏ខ្ពស់បំផុតលើផែនដីទាំងមូល» ។


ព្រះនាមរបស់ព្រះផ្ទាល់ជាភាសាហេព្រើរពីបុរាណ

ព្រះនាមយេហូវ៉ា (ឬក៏យ៉ាវេដូចជា *ព្រះគម្ពីរយេរូសាឡិម* ខាងកាតូលិកហើយវិជ្ជាករខ្លះនៅសម័យនេះចូលចិត្ត) មានជិត៧០០០ដងក្នុងបទគម្ពីរហេព្រើរដើម ។ កំណែថ្មីនៃព្រះគម្ពីរភាគច្រើន មិនបង្ហាញព្រះនាមព្រះផ្ទាល់ទេ ផ្ទុយទៅវិញគេដាក់ «ព្រះ» ឬក៏

«ព្រះអម្ចាស់» ជំនួសព្រះនាមដ៏ពិតនោះ។ យ៉ាងណាក៏ដោយ សូម្បីតែក្នុងព្រះគម្ពីរទាំងនោះ ជាធម្មតាមនុស្សម្នាក់ៗអាចដឹងកន្លែងដែលបទគម្ពីរហេព្រើរដើមបានប្រើព្រះនាមយេហូវ៉ា ពីព្រោះឋានន្តរដែលគេដាក់ជំនួសនោះ បានត្រូវសរសេរដោយអក្សរធំៗ។ តែកំណែថ្មីជាច្រើនដែលទាន់សម័យប្រើព្រះនាមយេហូវ៉ា ឬក៏ព្រះនាមយ៉ាវេ។ ហេតុដូច្នេះហើយ ព្រះគម្ពីរបានចែងនៅអេសាយ ៤២:៨ថា: ”អញជាយេហូវ៉ា នេះហើយជាឈ្មោះរបស់អញ”។

## ព្រះនាមទ្រង់ដែលមានការទាក់ទងទៅនឹងរឿងក្ដីតុលាការ

ដំណើររឿងនៃបទគម្ពីរដែលស្មរបន្ទាល់ព្រះយេហូវ៉ាប្រើដើម្បីទទួលយកឈ្មោះគេ គឺមកពីអេសាយជំពូកទី៤៣។ នៅបទគម្ពីរនោះ ព្រឹត្តិការណ៍ពិភពលោកទាំងមូល គឺចាត់ទុកជារឿងក្ដីនៅតុលាការ : ព្រះនានាពីសាសន៍ទាំងអស់បានត្រូវអញ្ជើញឱ្យនាំមកនូវសាក្សីរបស់គេ ដើម្បីបង្ហាញភស្តុតាងចំពោះបណ្ដឹងក្ដីដែលគេអះអាងថាគេជាអ្នកសុចរិត ឬក៏ដើម្បីឱ្យស្ដាប់ស្មរបន្ទាល់ខាងព្រះយេហូវ៉ា ហើយទទួលស្គាល់នូវសេចក្ដីពិតទៅវិញ។ ក្នុងបទគម្ពីរនោះ ព្រះយេហូវ៉ាបានប្រកាសទៅរាស្ត្ររបស់ទ្រង់ថា: ”ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ឯងរាល់គ្នាជាស្មរបន្ទាល់របស់អញ ហើយជាអ្នកបំរើដែលអញបានរើសតាំងដើម្បីឱ្យបានស្គាល់ ហើយជឿដល់អញព្រមទាំងយល់ថាគឺអញនេះហើយ ឥតមានព្រះណាកើតមកមុនអញទេ ហើយក្រោយអញក៏ឥតមានដែរ។ គឺអញ អញនេះហើយជាយេហូវ៉ា ក្រៅពីអញគ្មានអ្នកសង្គ្រោះណាទៀតឡើយ”។-អេសាយ ៤៣:១០-១១

ព្រះយេហូវ៉ាទ្រង់មានស្មរបន្ទាល់នៅលើផែនដី ក្នុងកំឡុងពេលរាប់ពាន់ឆ្នាំមុនព្រះគ្រិស្ទយាងមកម្ល៉េះ។ ក្រោយពីហេព្រើរជំពូកទី១១បានរៀបរាប់ពីមនុស្សខ្លះដែលប្រកបទៅដោយជំនឿ ហេព្រើរ ១២:១ បានចែងថា: «ដូច្នេះដែលមានស្មរបន្ទាល់១ហ្វូងធំម្ល៉េះនៅព័ទ្ធជុំវិញយើង នោះត្រូវឱ្យយើងចោលអស់ទាំងបន្ទុក នឹងអំពើបាបដែលរុំយើងជុំវិញជាងាយម្ល៉េះនោះចេញ។ ហើយត្រូវរត់ក្នុងទីប្រណាំង ដែលនៅមុខយើងដោយអំណត់»។ ព្រះយេស៊ូបានមានបន្ទូលនៅខាងមុខលោកប៉ុនទាស-ពីឡាត់ថា : «ខ្ញុំបានកើតមក ហើយក៏ចូលក្នុងលោកីយនេះ សំរាប់តែការនោះឯង ដើម្បីឱ្យខ្ញុំបានធ្វើបន្ទាល់ពីសេចក្ដីពិត»។ (យ៉ូហាន ១៨:៣៧; វិវរណៈ ៣:១៤)

ព្រះយេស៊ូមានបន្ទូលប្រាប់សិស្សទ្រង់ថា : «កាលណាព្រះវិញ្ញាណបរិសុទ្ធបានមកសណ្ឋិតលើអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងបានព្រះចេស្ដា ហើយនឹងធ្វើជាទីបន្ទាល់ពីខ្ញុំ នៅក្រុងយេរូសាឡិម ព្រមទាំងស្រុកយូដានឹងស្រុកសាម៉ារីទាំងមូល ហើយរហូតដល់ចុងផែនដីបំផុតផង»។– កិច្ចការ ១:៨

ហេតុដូច្នេះហើយមនុស្សប្រមាណ៦.000.000នាក់នៅជាង២៣0ប្រទេស ដែលកំពុងផ្សាយដំណឹងល្អនៃព្រះរាជាណាចក្ររបស់ព្រះយេហូវ៉ា ដែលគ្រប់គ្រងដោយព្រះយេស៊ូគ្រិស្ទយល់ថាជាការត្រឹមត្រូវណាស់ ដែលគេហៅខ្លួនគេជាស្មរបន្ទាល់ព្រះយេហូវ៉ា។

សាក្សីព្រះយេហូវ៉ាប្រមាណ

៦.000.000នាក់

នៅជាង២៣០ប្រទេស



---

* ការដកស្រង់បទគម្ពីរនៅក្នុងសៀវភៅស្ដើងនេះគឺចេញពីសេចក្ដីបកប្រែនេះ។ បើមាន *«ព.ថ.»* នៅបន្ទាប់ពីបទគម្ពីរណា នោះបញ្ជាក់ថាបទនោះបានដកស្រង់ចេញពី *សេចក្ដីបកប្រែពិភពលោកថ្មីនៃបទគម្ពីរបរិសុទ្ធ* ជាភាសាអង់គ្លេស។

Copyright © 2004 Watchtower Bible and Tract Society of Pennsylvania. All rights reserved.